AMS
អរិយធម៌ខ្មែរ
KHMER CIVILIZATION

# សិលាចារឹកប្រាសាទភ្នំដាច់ (ភាគ ១)

ប្រាសាទភ្នំដាច់ មានទីតាំងស្ថិតនៅក្នុងឃុំជាំក្សាន្ត ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ ដែលជាប្រាសាទសាងសង់ឡើងនៅលើកូនភ្នំមួយ មានប្រាង្គចំនួន២ ធ្វើអំពីឥដ្ឋ បែរមុខទៅទិសខាងកើត តែប្រាង្គដែលនៅឈរមានរូបរាង គឺនៅសល់តែមួយប៉ុណ្ណោះ (មួយទៀតបាក់បែកអស់)។ នៅឆ្នាំ២០២០ អ្នកស្រុកបានប្រមូលគ្នាមកកាប់ឆ្ការព្រៃកសាងវត្តអារាមមួយនៅលើភ្នំនេះ ក៏ប្រទះឃើញសិលាចារឹកចំនួន ២ ផ្ទាំង។ ក្រោយមក ខ្ញុំបាទបានជូនដំណឹងដល់ថ្នាក់ដឹកនាំក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ដើម្បីក្រសួងចាត់តាំងដល់មន្ត្រីមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តព្រះវិហារ ចុះប្រមូលយកសិលាចារឹកទាំងពីរផ្ទាំងមករក្សាទុកនៅក្នុងឃ្លាំងរក្សាវត្ថុបុរាណរបស់មន្ទីរ។ នៅក្នុងអត្ថបទខ្លីនេះ យើងនឹងសិក្សាសិលាចារឹកមួយផ្ទាំងសិនប៉ុណ្ណោះ និងបន្តពិភាក្សាមួយផ្ទាំងទៀតនៅភាគបន្ទាប់។

សិលាចារឹកផ្ទាំងទី១នេះ ចារឹកនៅលើថ្មកក់ដែលមានរាងជាបង្គោលសីមាតូចមួយ ដែលអក្សរនៅលើថ្មមានដំពៅពក់ខ្លាំងណាស់។ សិលាចារឹកនេះ ចារឹកជាភាសាខ្មែរបុរាណ មានចំនួន ១០ បន្ទាត់ ដោយមានចុះកាលបរិច្ឆេទមហាសករាជឆ្នាំ៨២២ ត្រូវនឹងគ្រឹស្តសករាជឆ្នាំ៩០០ (ដើម ស.វ.ទី១០) ដែលស្ថិតនៅក្នុងរជ្ជកាលព្រះបាទយសោវរ្ម័នទី១ (គ.ស.៨៨៩ - ៩១០)។ អ្វីដែលគួរឱ្យសោកស្តាយនោះ គឺផ្នែកខ្លះនៃសិលាចារឹកមានការរលុបអក្សរដោយអន្ទើ។ ម្យ៉ាងវិញទៀត ប្រសិនបើមើលតាមរូបរាងអក្សរ សិលាចារឹកនេះទំនងចារឹកឡើងនៅសម័យក្រោយ តែរំឭកសាច់រឿងទៅព្រឹត្តិការណ៍នៅមហាសករាជឆ្នាំ៨២២។

នៅក្នុងអត្ថបទសិលាចារឹកនេះ មិនមានរំលេចអំពីព្រះនាមព្រះមហាក្សត្រនោះឡើយ គឺគ្រាន់ជាប្រភេទរាជសាសន៍ ដែលព្រះមហាក្សត្រទ្រង់ត្រាស់បង្គាប់ឱ្យមន្ត្រីជាន់ខ្ពស់ជាច្រើនរូបនាំយករាជបញ្ជានោះទៅត្រាស់បង្គាប់ដល់ វាបបញ្ចគវ្យ ***(វាប ជាគោរម្យងាររបស់មន្ត្រីថ្នាក់តំបន់ រីឯបញ្ចគវ្យ សំដៅដល់ទឹកដោះគោចំនួនប្រាំប្រភេទដែលគេថ្វាយដល់ព្រះ)*** ដែលជាប្រធានគ្រប់គ្រងផ្នែកទាំង៧ ថាពល់ព្រះតង្វាយទាំងអស់សម្រាប់ថ្វាយព្រះនៅទេវស្ថាន គឺមិនស្ថិតក្រោមការគ្រប់គ្រងរបស់ភ្នាក់ងារផ្សេងៗនៃអាជ្ញាធរមូលដ្ឋានឡើយ ***(ទំនងចង់សំដៅពល់តង្វាយ គឺត្រូវមិនបង់ពន្ធឡើយ)***។

### អត្ថបទពាក្យចារឹក

១. សិទ្ធិស្វស្តិជយ ៙ ៨២២ ឥក តតិ អឞ្ទមិ

២. ....ឧ មាឯ ពៃះ កា[ស]ណា ឌូលិ ព្រះចាឧ ឌូលិជេង ព្រះ

អត្ថបទដោយ៖ កំ វណ្ណារ៉ា

៣.	កម្រតេងអញ ត កម្រតេងអញ ស្រីជយេន្ទ្របណ្ឌិត ឆ្នុ ម្រ

៤.	តេញ ខ្ញោញ ស្រីប្ឫថវីន្ទ្រវិជយ្យ ឆ្នុ ស្តេញ..វកុល ឆ្នុ

៥.	ម្រតាញ ស្រីវល្ភសណ្ឋារ ឆ្នុ តាញ ស្រីឆ្នបេន្ទ្រវិក្រម ប្រែ ចាំប

៦.	ញ្ជូតវ្យមូលបំចាំប្រំវ្យលិមោគិស្ថាបនាព្រះសាសណាវ្ំជាបិខ្ញោញ

៧.	ញ ច្រលោ ខ្ញោញ ...ស្ថបនា វ្ំជា ខ្ញោញ ព្រិហិ

៨.	ស្រុក ជា ព្រះហ បំចាំ.................ព្រះហ វ្ំ ជា បិ ខ្ញោញ ព្រះហ

៩.	.....អ្នក ទៅ......តិ បិធារ ទៅ

១០.	...ត តិ ព្រះ.........................យ

**បំណកប្រែ**

*សិទ្ធិស្វស្តិជយ ៙ សេចក្ដីសម្រេច សួស្ដី ជ័យជម្នះ មហាសករាជឆ្នាំ ៨២២ ថ្ងៃទី៨ ....ព្រះមហាក្សត្រ ទ្រង់មានព្រះរាជឱង្ការត្រាស់ (សេចក្ដីណែនាំ) បង្គាប់ព្រះកម្រតេងអញស្រីជយេន្ទ្របណ្ឌិត ម្រតេងខ្ញោញស្រីប្ឫថវីន្ទ្រវិជយ្យ ស្តេញ..វកុល ម្រតាញស្រីវល្ភសណ្ឋារ តាញស្រីឆ្នបេន្ទ្រវិក្រម ត្រាស់បង្គាប់ដល់ វាបបញ្ចូតវ្យ ជាមូលបំចាំប្រាំពីរ (ប្រធានក្រុមប្រចាំការទាំង៧) ដើម្បីឱ្យមកស្ថាបនាព្រះសាសន៍ (អនុវត្តតាមរាជឱង្ការ) ថា មិនស្ថិតក្រោមខ្ញោញច្រលោ, ខ្ញោញ ..., ខ្ញោញវ្រិហិ (ប្រធានភ្នាក់ងារខាងពន្ធដារស្រូវ)......សម្រាប់ថ្វាយព្រះ, ខ្ញោញ ......អ្នកទៅ...គឺគប្បីទទួល ទៅ .....គឺព្រះ..........។*

*ជារួមមក សិលាចារឹកផ្ទាំងទី១ដែលរកឃើញនៅប្រាសាទភ្នំដាច់ ខេត្តព្រះវិហារនេះ គឺជាប្រភេទសិលាចារឹកខ្ចីមួយដែលរៀបរាប់អំពីព្រះរាជសាសន៍របស់ព្រះមហាក្សត្រ ត្រាស់បង្គាប់ឱ្យមន្ត្រីរបស់ទ្រង់នាំយករាជបញ្ជា ទៅដល់មន្ត្រីនៅមូលដ្ឋានអំពីរឿងរ៉ាវពាក់ព័ន្ធនឹងគ្រឿងតង្វាយសម្រាប់ព្រះនៅទេវស្ថាន។*

*អត្ថបទដោយ៖ កំ វណ្ណារ៉ា*



រូបលេខ១៖ ប្រាសាទភ្នំដាច់ មើលពីទិសខាងកើត



រូបលេខ២៖ ប្រាសាទភ្នំដាច់ មើលពីទិសឦសាន

អត្ថបទដោយ៖ កំ វណ្ណាក់



រូបលេខ៣៖ សិលាចារឹកផ្ទាំងទី១ រកឃើញនៅប្រាសាទភ្នំដាច់



រូបលេខ៤៖ ក្រដាសផ្តិតសិលាចារឹកប្រាសាទភ្នំដាច់ (ផ្តិតដោយ៖ កំ វណ្ណារ៉ា)

អត្ថបទដោយ៖ កំ វណ្ណារ៉ា